**រដ្ឋសភា**

# ជម្រាបជូន
# សម្តេចក្រឡាហោម ស ខេង
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**តាមរយៈ** ៖ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

**កម្មវត្ថុ** ៖ សំណើសុំការពន្យល់ និងបកស្រាយជាលាយលក្ខណ៍អក្សរអំពីៈ
-ប្រកាសលេខ៤០៧៩ ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃស្តីពីការកែសម្រួលប្រការ២ និងប្រការ៦ នៃប្រកាសលេខ១០២៤៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី នីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត និង
-លិខិតរដ្ឋបាលចេញដោយអាជ្ញាធរក្រុង ស្រុក ខណ្ឌមួយចំនួនណែនាំដល់អាជ្ញាធរឃុំ សង្កាត់ដើម្បីអនុវត្តនាពេលថ្មីៗនេះ។

**យោង** ៖ -មាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ
-ប្រការ៣២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
-ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **សម្តេចក្រឡាហោម** ជ្រាបថា នាពេលថ្មីៗនេះក្រសួងមហាផ្ទៃ និងអាជ្ញាធរក្រុង ស្រុក ខណ្ឌ បានចេញលិខិតរដ្ឋបាលមួយចំនួនដូចជាៈ

១-ប្រកាសលេខ៤០៧៩ ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការកែសម្រួលប្រការ២ និងប្រការ៦ នៃប្រកាសលេខ១០២៤៥ ប្រក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី នីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋសម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។ ប្រកាសនេះបានបង្កការលំបាកដល់ប្រជាពលរដ្ឋ ដោយកំណត់រយៈពេលនៃការស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅ (យ៉ាងតិច៣០ថ្ងៃ) និងដកសិទ្ធិពីមេឃុំ ចៅសង្កាត់ដែលកន្លងមកមានភារកិច្ចទទួលខុសត្រូវលើការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ ដូចមានចែងក្នុងប្រកាសក្រសួងមហាផ្ទៃបានចេញកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥។

២-លិខិតរដ្ឋបាលខណ្ឌសែនសុខលេខ២០៩ ល.ស ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលនីតិវិធី នៃការផ្ទេរសិទ្ធិអចលនទ្រព្យ ដែលមិនទាន់ចុះបញ្ជី ដែលលិខិតនេះបំពានទៅនឹងការអនុវត្តធ្លាប់មានកន្លងមក ជាពិសេសផ្ទុយនឹងប្រការ ៩ ថ្មី នៃប្រកាសអន្តរក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ ស្តីពី "ការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ក្នុងការចុះបញ្ជីដីធ្លី" លេខ១៥៩ ប្រក/ដនស/មផ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦។ ហើយក្រសួងទាំងពីរមិនបានប្រតិភូកម្មអំណាច និងមុខងារនេះទៅឲ្យស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយដូចកំណត់នៅក្នុងមាត្រា៩ នៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ និងមាត្រា១៨

នៃអនុក្រឹត្យលេខ១៨ អនក្រ-បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣-លិខិតរដ្ឋបាលលេខ០៤៣/១៧ សងក.រប ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ស្តីពី"អង្គការដៃគូរនានា ដែលចុះធ្វើសកម្មភាពក្នុងឃុំ" ដែលលិខិតនេះមិនបានបញ្ជាក់ប្រភពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាក់លាក់ ដើម្បីឲ្យមេឃុំយកជាមូលដ្ឋានក្នុងការបង្គាប់ឲ្យអង្គការ និងសមាគមដែលចុះបញ្ជីត្រឹមត្រូវទៅសុំការអនុញ្ញាតពីរដ្ឋបាលស្រុក មុននឹងធ្វើសកម្មភាពនៅក្នុងឃុំ។ មាត្រា១១ នៃអនុក្រឹត្យ ស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ បានចែងថា "ក្រុមប្រឹក្សាត្រូវលើកស្ទួយ និងសម្របសម្រួលក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយត្រូវរកប្រភពជំនួយឥតសំណង និងកៀងគរសមត្ថភាព និងធនធានពី៖....អង្គការជាតិ និងអន្តរជាតិ និងអង្គការនានានៅមូលដ្ឋាន..." មាត្រា១២ បានតម្រូវឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ "សម្របសម្រួល និងលើកស្ទួយយ៉ាងសកម្មនូវការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យក្នុងឃុំ សង្កាត់ ដោយត្រូវបង្កើតឡើងនូវយន្តការដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិល និងសហគមន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន"។

៤-សេចក្តីសម្រេចលេខ០១៧ សសរ រហ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ ស្តីពី "ការចាត់តាំងមន្ត្រីកិច្ចសន្យាចំនួន ១៩រូប ឲ្យទៅបំពេញការងារនៅសង្កាត់ទាំង៦នៃខណ្ឌសែនសុខ" ដែលលិខិតនេះបំពានទៅនឹងមាត្រា២៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានចែងថា "ឃុំ សង្កាត់ អាចជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ ដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការ និងការចាំបាច់នៃការងារ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់"។

ប្រកាស និងលិខិតរដ្ឋបាលខាងលើនេះបានធ្វើឲ្យមានការងឿងឆ្ងល់យ៉ាងខ្លាំងពីមតិសាធារណៈចំពោះមូលហេតុនៃភាពខុសគ្នាក្នុងការអនុវត្តធ្លាប់មានកន្លងមក និងការអនុវត្តក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម** មេត្តាពន្យល់ និងបកស្រាយជាលាយលក្ខណ៍អក្សរ ដោយក្តីអនុគ្រោះ។

សូម **សម្តេចក្រឡាហោម** ទទួលនូវការគោរព អំពីយើងខ្ញុំ៕

លេខ:.......:..........

បានឃើញ និងបានបញ្ជូនមក

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

"ដើម្បីមុខការ"

រាជធានីភ្នំពេញ ថ្ងៃទី......ខែ...........ឆ្នាំ២០១៧

**ប្រធានរដ្ឋសភា**

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧

**អ្នកតំណាងរាស្ត្រ**

ម៉ូ សុខួរ, សំរង្ស៊ី ភីនទ័រ, ... វណ្ណ ដាវ៉ាត, ... [handwritten signatures]